**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

**អង្គបុរេជំនុំជម្រះ**
Pre-Trial Chamber
Chambre Preliminaire

*ក្នុងនាមប្រជារាស្ត្រខ្មែរ និងក្នុងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ៦០)

ចំពោះមុខ: **ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន**
**ចៅក្រម** Olivier BEAUVALLET
**ចៅក្រម ន័យ ថុល**
**ចៅក្រម** Kang Jin Baik
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: ថ្ងៃទី ០៣ ខែឧសភា ឆ្នាំ ២០១៩

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 03 / 05 / 2019
ម៉ោង (Time/Heure): 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**សាធារណៈ**

## ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ

---

**<u>សហព្រះរាជអាជ្ញា៖</u>**

ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវីការពារក្តី អោ អាន៖</u>**

មុំ លុច
Richard ROGERS
Göran SLUITER

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ÷</u>**

ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉ែន ពៅ

Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Nushin SARKARATI



ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ០២៣-២១៩-៨១៤ ទូរសារ (៨៥៥) ០២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**បានទទួល**បណ្តឹងឧទ្ធរណ៍ដាក់ដោយសហព្រះរាជអាជ្ញាជាតិ[1]នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ បណ្តឹងឧទ្ធរណ៍ដាក់ដោយសហមេធាវីការពារក្តី អោ អាន[2] នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ដែលចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០១៨ នៅក្នុងសំណុំរឿង ០០៤/២[3] និងបណ្តឹងឧទ្ធរណ៍ដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ នៅថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១៨[4] ប្រឆាំងនឹងដីកាលើកលែងចោទប្រកាន់ អោ អាន (ឯកសារ D359)ចេញដោយសហចៅក្រមស៊ើបអង្កេតជាតិនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ នៅក្នុងសំណុំរឿង ០០៤/២[5]។

**យល់ឃើញ**ថា សារណាបណ្តឹងឧទ្ធរណ៍នៅក្នុងសំណុំរឿងនេះ បានចប់សព្វគ្រប់ហើយ។

**បានឃើញ** សេចក្តីសន្និដ្ឋាននានាអំពីសវនាការនេះ ដែលជាការឆ្លើយតបទៅនឹងសេចក្តីជូនដំណឹងរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩[6] ដោយសហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ចម្លើយតប[7] នៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ ហើយសហព្រះរាជអាជ្ញាជាតិ[8] និងសហមេធាវីការពារក្តី អោ អាន[9] បានដាក់ចម្លើយតបនៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩។

---

[1] សំណុំរឿង០០៤/២/០៧-០៩-២០០៩-អវតក-កសចស (“សំណុំរឿង ០០៤/២”) បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ D360/8/1។

[2] សំណុំរឿង០០៤/២ បណ្តឹងឧទ្ធរណ៍របស់ អោ អាន លើដីកាដំណោះស្រាយ(ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ D360/5/1។

[3] សំណុំរឿង០០៤/២ ដីកាដំណោះស្រាយ(ដីកាបញ្ជូនទៅជំនុំជម្រះ) ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360។

[4] សំណុំរឿង០០៤/២ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (D359) ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ D359/3/1។

[5] សំណុំរឿង ០០៤/២ ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D359។

[6] សំណុំរឿង០០៤/២ អង្គបុរេជំនុំជម្រះជូនដំណឹងភាគីតាមរយៈអ៊ីមែល ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩ ម៉ោង ១០.៤៥ ព្រឹក។

[7] សំណុំរឿង០០៤/២ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះអំពីសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ ឯកសារ D359/4។

[8] សំណុំរឿង០០៤/២ ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះអំពីសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩ ឯកសារ D360/13។



PRE-TRIAL CHAMBER · E.C.C.C. · C

**អនុលោមតាមវិធានផ្ទៃក្នុង** ៧៧(៣), ៧៧(៥) និង ៧៧(៦)។

**អាស្រ័យហេតុនេះ ចេញដីកាបង្គាប់ថា** សវនាការនឹងត្រូវធ្វើឡើងនៅក្នុងបន្ទប់សវនាការធំ នៅថ្ងៃពុធ ទី១៩ ខែមិថុនា ឆ្នាំ២០១៩ ថ្ងៃព្រហស្បតិ៍ ទី២០ ខែមិថុនា ឆ្នាំ២០១៩ និងថ្ងៃសុក្រ ទី២១ ខែមិថុនា ឆ្នាំ២០១៩ ហើយ**ជូនដំណឹង**ភាគីថា តារាងពេលវេលាសម្រាប់សវនាការនេះមានដូចខាងក្រោម៖

**ថ្ងៃពុធ ទី១៩ ខែមិថុនា ឆ្នាំ២០១៩**

ម៉ោង ១០:០០-១០:១៥ សេចក្តីផ្តើមបើកសវនាការ (១៥ នាទី)

ម៉ោង ១០:១៥-១០:៤៥ អង្គជំនុំជម្រះធ្វើសេចក្តីរាយការណ៍អំពីសំណុំរឿង (៣០ នាទី)

ម៉ោង ១០:៤៥-១១:៤៥ សារណាបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ(១ ម៉ោង)

ម៉ោង ១១:៤៥-១៣:១៥ *សម្រាក (១ ម៉ោង កន្លះ)*

ម៉ោង ១៣:១៥-១៥:១៥ សារណាបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ( ២ ម៉ោង)

**ថ្ងៃព្រហស្បតិ៍ ទី២០ ខែមិថុនា ឆ្នាំ២០១៩**

ម៉ោង ០៩:៣០-១២:០០ សារណាបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តីជាតិ/អន្តរជាតិ(២ ម៉ោង កន្លះ)

ម៉ោង ១២:០០-១៣:៣០ *សម្រាក (១ ម៉ោង កន្លះ)*

ម៉ោង ១៣:៣០-១៤:៣០សារណាតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ( ១ ម៉ោង)

ម៉ោង ១៤:៣០-១៦:០០ សារណាតបរបស់សហមេធាវីការពារក្តីជាតិ/អន្តរជាតិ( ១ ម៉ោង កន្លះ)

---

[9]សំណុំរឿង០០៤/២ ចម្លើយតបរបស់ អោ អាន ទៅនឹងសេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះអំពីសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩ ឯកសារ D360/12។

**ថ្ងៃសុក្រ ទី២១ ខែមិថុនា ឆ្នាំ២០១៩**

ម៉ោង ១០:០០-១១:៣០ ប្រសិនបើចាំបាច់ អង្គជំនុំជម្រះតាំងសំណួរទៅភាគី។ សេចក្តីជូនដំណឹង និងព័ត៌មានពាក់ព័ន្ធនឹងផ្តល់ជូននៅថ្ងៃព្រហស្បតិ៍ ទី២០ ខែមិថុនា ឆ្នាំ២០១៩ (១ ម៉ោងកន្លះ)

**ជូនដំណឹង**ថា ប្រសិនបើជនត្រូវចោទមានវត្តមាន និងនៅពេលដែលជូនដំណឹងតាមរយៈមេធាវីរបស់ខ្លួន ជនត្រូវចោទមានសិទ្ធិធ្វើសេចក្តីសន្និដ្ឋានផ្ទាល់ខ្លួននៅពេលចុងបញ្ចប់បិទសវនាការ។

**បង្គាប់**ថា ប្រសិនបើជនត្រូវចោទមិនអាចមានវត្តមានដោយសារមូលហេតុសុខភាព ត្រូវដាក់សេចក្តីបញ្ជាក់ពីគ្រូពេទ្យជូនអង្គជំនុំជម្រះ។

**សម្រេច**ថា សវនាការនេះនឹងត្រូវធ្វើឡើងជាសាធារណៈរហូតដល់ពេលដែលអង្គជំនុំជម្រះបានអានចប់ទាំងស្រុងនូវសេចក្តីរាយការណ៍អំពីសំណុំរឿង បន្ទាប់មក សវនាការនឹងត្រូវធ្វើឡើងដោយសម្ងាត់។

**រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែឧសភា ឆ្នាំ ២០១៩**

**ប្រធានអង្គជំនុំជម្រះ**

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE
E.C.C.C * C.E.T.C

**ប្រាក់ គឹមសាន**